DISRUPTING HARM

# ការពារកុមារនៅក្នុងប្រទេសកម្ពុជាពីការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ៖ ផ្លូវឆ្ពោះទៅមុខ

កុមារនៅកម្ពុជាកំពុងប្រឈមមុខនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ (OCSEA) ។ យោងលើការស្ទង់មតិតាមខ្នងផ្ទះដែលមានលក្ខណៈតំណាងជាតិ ១១% នៃកុមារដែលប្រើអ៊ីនធឺណិត អាយុពី ១២-១៧ ឆ្នាំ បានទទួលរងគ្រោះថ្នាក់ដោយឧទាហរណ៍ច្បាស់លាស់នៃអំពើ OCSEA នៅក្នុងឆ្នាំមុន។ នេះរួមបញ្ចូលទាំងកុមារដែលត្រូវបានគំរាមឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ កុមារដែលរូបភាពផ្លូវភេទរបស់ខ្លួនត្រូវបានគេចែកចាយដោយគ្មានការអនុញ្ញាត ឬកុមារដែលត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទតាមរយៈការសន្យាផ្តល់ប្រាក់ ឬអំណោយ។ ច្បាប់នៅក្នុងប្រទេសកម្ពុជាដែលដោះស្រាយអំពើ OCSEA គឺមានលក្ខណៈទូលំទូលាយ ប៉ុន្តែមានឧបសគ្គមួយចំនួននៅក្នុងការអនុវត្តច្បាប់ទាំងនេះ។ ការយល់ដឹងជាសាធារណៈអំពីហានិភ័យ និងគ្រោះថ្នាក់ដែលកុមារប្រឈមនៅលើប្រព័ន្ធអនឡាញនៅមានកម្រិតទាបនៅឡើយ ហើយកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ត្រូវការការកែលម្អបន្ថែម។ការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់ផ្តល់នូវជំហានច្បាស់លាស់ និងជាបន្ទាន់ចាំបាច់ត្រូវធ្វើ ដើម្បីបញ្ឈប់គ្រោះថ្នាក់នៃការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញចំពោះកុមារ នៅក្នុងប្រទេសកម្ពុជា។

## សកម្មភាពដែលត្រូវបានផ្តល់អនុសាសន៍

ការប្រយុទ្ធប្រឆាំងនឹងអំពើ OCSEA និងការផ្តល់ការគាំទ្រកាន់តែប្រសើរឡើងដល់ជនរងគ្រោះទាមទារឱ្យមានសកម្មភាពដ៏ទូលំទូលាយ និងប្រកបដោយនិរន្តរភាពពីអ្នកធ្វើគោលនយោបាយ អ្នកអនុវត្តច្បាប់ អ្នកជំនាញផ្នែកគាំទ្រសង្គម និងយុត្តិធម៌ ក្រុមហ៊ុនឧស្សាហកម្មបច្ចេកវិទ្យា និងសហគមន៍ទាំងមូល។ *ការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា* ដាក់ចេញនូវផែនការសកម្មភាពដែលអាចអនុវត្តបាន ដើម្បីការពារកុមារតាមរយៈអនុសាសន៍ដែលផ្អែកលើភស្តុតាងជាស៊េរី និងគ្របដណ្តប់លើច្បាប់ ការអនុវត្តច្បាប់ ដំណើរការផ្លូវច្បាប់ សេវាសង្គមកិច្ច និងការយល់ដឹងជាសាធារណៈ។ អនុសាសន៍ទាំងនេះអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជា និងដៃគូរបស់ខ្លួនធ្វើសកម្មភាព អប់រំ និងវិនិយោគ។

## ធ្វើសកម្មភាព

- ធ្វើវិសោធនកម្មច្បាប់ឱ្យស្របតាមស្តង់ដារនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ការធ្វើពេស្យាចារកុមារ និងរូបភាពឬសម្ភារអាសអាភាសកុមារ អនុសញ្ញា Lanzarote និងអនុសញ្ញាទីក្រុង Budapest ។
- *ចាត់ជាបទល្មើសព្រហ្មទណ្ឌចំពោះ*អំពើផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ អំពើលួងលោមតាមអនឡាញ និងអំពើគំរាមខាងផ្លូវភេទ។
- តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅកម្ពុជា (២០២១-២០២៥)។

Funded by End Violence Against Children

Implemented by ecpat INTERPOL unicef Office of Research-Innocenti

DISRUPTING HARM

- ពង្រឹងការប្រមូលទិន្នន័យ និងការតាមដានករណី OCSEA នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។
- បង្កើត និងរក្សាតំណភ្ជាប់ទៅនឹងប្រព័ន្ធទិន្នន័យអន្តរជាតិនៃករណីកេងប្រវ័ញ្ចផ្លូវភេទកុមារ របស់អង្គភាព INTERPOL ដើម្បីជួយសម្រួលដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងលុបបំបាត់ភាពជាន់គ្នានៃកិច្ចខិតខំប្រឹងប្រែង។ ប្រព័ន្ធទិន្នន័យនេះគឺជាឧបករណ៍ប្រមូលព័ត៌មានសម្ងាត់ និងស៊ើបអង្កេតដែលអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតជំនាញចែករំលែកទិន្នន័យពាក់ព័ន្ធនឹងករណីរំលោភបំពានផ្លូវភេទកុមារ។
- គាំទ្រដល់ការបង្កើតយន្តការដ៏មានប្រសិទ្ធភាពមួយ ដើម្បីធានាថាការបញ្ជូនករណី OCSEA ជាអន្តរជាតិ ទទួលបានការស៊ើបអង្កេតដោយនគរបាលក្នុងកម្រិតដ៏សមស្របមួយ។
- បង្កើនការយល់ដឹងអំពីបណ្ដាញរាយការណ៍បន្ទាន់ និងបណ្ដាញទូរស័ព្ទជំនួយដែលមានស្រាប់ ថាជាយន្តការរាយការណ៍ និងស្វែងរកជំនួយសម្រាប់ករណី OCSEA ។
  - ពន្លឿននីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌពាក់ព័ន្ធនឹងកុមាររងគ្រោះពីអំពើ OCSEA តាមរយៈការបង្កើតទំនាក់ទំនងក្នុងលក្ខណៈសហការរវាងស្ថាប័នអនុវត្តច្បាប់ និងបណ្ដាញទំនាក់ទំនងសង្គម និងថ្នាលកម្មវិធីផ្ញើសារភ្លាមៗ ជាសកល និងក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតជាតិ ដើម្បីគាំទ្រដល់ការស៊ើបអង្កេត និងការផ្ដន្ទាទោសបានទាន់ពេលវេលា។
  - ជៀសវាងការដកហូតកុមាររងគ្រោះចេញពីគ្រួសារ និងសហគមន៍ដោយមិនចាំបាច់។ ប្រសិនបើកុមារត្រូវដកចេញពីផ្ទះ ឬសហគមន៍របស់ពួកគេ ការវាយតម្លៃគួរតែត្រូវបានធ្វើឡើងដើម្បីកំណត់ថាតើនេះជាឧត្តមប្រយោជន៍របស់កុមារដែរឬទេ។ ប្រសិនបើសេវាទាក់ទងនឹងជម្រកត្រូវប្រើប្រាស់ វាគួរតែមានរយៈពេលខ្លីបំផុតតាមដែលអាចធ្វើបាន ហើយលក្ខខណ្ឌនានាគួរតែអនុលោមតាមបទដ្ឋានអន្តរជាតិ។
  - ទទួលយកអភិក្រមច្រកចេញចូលតែមួយ ដើម្បីគាំទ្រកុមារដែលរងគ្រោះដោយអំពើ OCSEA លើដំណើរចូលរួមរបស់ពួកគេក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងគោលបំណងជៀសវាងការប៉ះទង្គិចផ្លូវចិត្តឡើងវិញដែលអាចកើតឡើងពីការសុំឱ្យកុមាររៀបរាប់ម្ដងហើយម្ដងទៀតពីការរំលោភបំពានរបស់ពួកគេច្រើនដង ក្នុងអំឡុងពេលដំណើរការយុត្តិធម៌។
  - បង្កើត និងអនុវត្តកម្មវិធីដែលរៀបចំកុមាររងគ្រោះចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។
  - បង្កើតដំណើរការរាយការណ៍ និងបញ្ជូនឱ្យបានច្បាស់លាស់សម្រាប់ករណី OCSEA និងធានាថាអ្នកផ្ដល់សេវាទាំងអស់ត្រូវបានបណ្ដុះបណ្ដាលយ៉ាងត្រឹមត្រូវ ដើម្បីអនុវត្តដំណើរការនេះតាមរបៀបកុមារមេត្រី។
  - ផ្ដល់កញ្ចប់ព័ត៌មានជាស្ដង់ដារដល់មន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ដើម្បីជូនដំណឹងដល់ជនរងគ្រោះនៃ OCSEA និងអ្នកថែទាំរបស់ពួកគេអំពីនីតិវិធី និងសិទ្ធិពាក់ព័ន្ធទាំងអស់ រួមទាំងសំណង។

## អប់រំ

- ធានាឱ្យបាននូវការបណ្ដុះបណ្ដាលជាចាំបាច់ និងទៀងទាត់លើប្រធានបទ OCSEA និងហានិភ័យតាមប្រព័ន្ធអនឡាញផ្សេងទៀតសម្រាប់អ្នកជំនាញទាំងអស់ដែលមានទំនាក់ទំនងជាមួយកុមារ។ នេះនឹងធានាថាពួកគេយល់ដឹងពីការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល និងទម្រង់ថ្មីៗនៃការរំលោភបំពាន។ បញ្ចូលការលើកកម្ពស់ចំណេះដឹងអំពី OCSEA ទៅក្នុងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈដែលមានស្រាប់ ដូចជានៅក្នុងសាលាបណ្ឌិតសភានគរបាល ឬវគ្គសិក្សាកម្រិតវិញ្ញាបនបត្រសម្រាប់បុគ្គលិកសង្គមកិច្ច។
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ រួមទាំងអំពីមធ្យោបាយដែលបច្ចេកវិទ្យាឌីជីថលអាចនឹងត្រូវបានប្រើប្រាស់ដោយជនល្មើស ដើម្បីប្រព្រឹត្ត ឬសម្របសម្រួលដល់ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ។
- វិនិយោគលើអក្ខរកម្មឌីជីថល និងកម្មវិធីសុវត្ថិភាពឌីជីថលសម្រាប់កុមារ និងអ្នកថែទាំ រួមទាំងអំពីហានិភ័យនៃការចែកចាយមាតិកាដែលមានលក្ខណៈផ្លូវភេទតាមប្រព័ន្ធអនឡាញ។ បង្រៀនកុមារអំពីផ្លូវភេទ ការយល់ព្រម ហានិភ័យ និងសិទ្ធិរបស់ពួកគេក្នុងការទទួលបានការការពារពី អំពើ OCSEA ។
- បង្រៀនអ្នកថែទាំអំពីថ្នាលកម្មវិធីឌីជីថល/បច្ចេកវិទ្យា និងសុវត្ថិភាពអនឡាញ រួមទាំងអំពីហានិភ័យផ្សេងៗនៃ OCSEA ផងដែរ។ គាំទ្រអ្នកថែទាំក្នុងការអភិវឌ្ឍជំនាញដើម្បីចូលរួមជាមួយកុមារដែលស្ថិតក្នុងការថែទាំរបស់ពួកគេជុំវិញប្រធានបទអំពីផ្លូវភេទ និងសុខភាពភេទ ការយល់ព្រម និងព្រំដែន ក្នុងគោលបំណងលើកទឹកចិត្តឱ្យមានការសន្ទនាអំពីការកំណត់សម្គាល់ និងឆ្លើយតបការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទ ទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញ។

Funded by End Violence Against Children

Implemented by ecpat INTERPOL unicef Office of Research-Innocenti

- ត្រូវប្រាកដថាកម្មវិធី និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការអប់រំ ទាំងឡាយគឺត្រូវផ្អែកលើភស្តុតាង និងត្រូវបានបង្កើតឡើងតាមរយៈការពិគ្រោះយោបល់ជាមួយកុមារ អ្នកថែទាំ និងគ្រូបង្រៀន ប្រកបដោយសុវត្ថិភាព និងក្រមសីលធម៌ ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។ តាមដាន វាយតម្លៃ និងកែប្រែកម្មវិធី និងយុទ្ធនាការទាំងនេះ ជាទៀងទាត់ ដើម្បីបញ្ជាក់ថាវាមានផលជះដែលចង់បាន ហើយមិនបណ្តាលឱ្យមានគ្រោះថ្នាក់ដោយអចេតនា។

## វិនិយោគ

- បែងចែកធនធានសម្រាប់ការបង្ការ និងឆ្លើយតបទៅនឹង OCSEA ។ ធានាបាននូវថវិកាគ្រប់គ្រាន់សម្រាប់ធ្វើគោលនយោបាយ និងការសម្របសម្រួលជារួម ព័ត៌មានសាធារណៈ និងការអប់រំ ព្រមទាំងការពង្រឹងអំណាចរបស់កុមារ។ បង្កើតឱ្យមានកញ្ចប់ថវិកាគាំទ្រដល់ការបណ្តុះបណ្តាលបច្ចេកទេសលើបញ្ហា OCSEA សម្រាប់មន្ត្រីនគរបាល ព្រះរាជអាជ្ញា ចៅក្រម/ចៅក្រមជំនុំជម្រះ មេធាវី មន្ត្រីក្នុងបន្ទប់សវនាការ មន្ត្រីកិច្ចការពារកុមារ បុគ្គលិកពេទ្យ បុគ្គលិកសង្គមកិច្ចជួរមុខ និងគ្រូបង្រៀន ដើម្បីធានាថាពួកគេតាមទាន់បច្ចុប្បន្នភាពជាទៀងទាត់លើទម្រង់នៃការរំលោភបំពានដែលវិវត្តន៍យ៉ាងឆាប់រហ័ស។
- បែងចែកមូលនិធិដើម្បីផ្តល់ធនធានសមរម្យដល់ការអនុវត្តផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា (២០២១-២០២៥)។
- ធានាថាមានសេវាសង្គមកិច្ច (រួមទាំង ផ្នែកវេជ្ជសាស្ត្រ ច្បាប់ ផ្លូវចិត្ត និងសមាហរណកម្ម)សម្រាប់កុមាររងគ្រោះ នៅទូទាំងប្រទេស រួមទាំងនៅតំបន់ជនបទផងដែរ។
- វិនិយោគលើគុណភាព និងលទ្ធភាពទទួលបានសេវាគាំទ្រផ្លូវចិត្តសម្រាប់ជនរងគ្រោះ និងអ្នករស់រានមានជីវិតនៃអំពើ OCSEA។
- ផ្តល់ធនធាន និងការបណ្តុះបណ្តាលដល់បុគ្គលិកបណ្តាញទូរស័ព្ទជំនួយកុមារ ដើម្បីឱ្យពួកគេអាចផ្តល់ព័ត៌មាន និងដំបូន្មានប្រកបដោយគុណភាពល្អ។  បណ្តាញទូរស័ព្ទជំនួយអាចត្រូវបានផ្សព្វផ្សាយជាប្រភពនៃការផ្តល់ព័ត៌មាន និងការគាំទ្រសម្រាប់កុមារដែលរងគ្រោះពីអំពើ OCSEA ក៏ដូចជាសម្រាប់មិត្តភ័ក្តិ អ្នកថែទាំ ឬអ្នកផ្សេងទៀតអំពីរបៀបដែលពួកគេអាចគាំទ្រយុវជនវ័យក្មេងដែលនិយាយប្រាប់ពីការរំលោភបំពាន។
- វិនិយោគលើឧបករណ៍ បរិក្ខារចាំបាច់ និងការកសាងសមត្ថភាពដែលត្រូវការ ដើម្បីឱ្យអ្នកអនុវត្តច្បាប់អាចធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងករណី OCSEA រួមទាំងការស៊ើបអង្កេតបែបបុរេសកម្ម។
- ផ្តល់ធនធានដល់នគរបាល និងបណ្តាញរាយការណ៍បន្ទាន់ ដើម្បីធ្វើឱ្យការប្រមូលទិន្នន័យ និងការតាមដានករណី OCSEA ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានកាន់តែប្រសើរឡើង។ ការកត់ត្រា និងចាត់ចំណាត់ថ្នាក់ករណីជាប្រព័ន្ធនឹងជួយសម្រួលដល់ការបង្កើតយន្តការទប់ស្កាត់ និងឆ្លើយតបដោយផ្អែកលើភស្តុតាង ចំពោះករណី OCSEA ។

របាយការណ៍ទាំងស្រុង និងបញ្ជីអនុសាសន៍ពេញលេញអាចរកបាននៅលើ៖ [link here]

Funded by End Violence Against Children

Implemented by ecpat INTERPOL unicef Office of Research-Innocenti

# ការយល់ដឹងស៊ីជម្រៅសំខាន់ៗ

តាមរយៈសកម្មភាពស្រាវជ្រាវផ្សេងៗ*គ្រោះថ្នាក់នៅកម្ពុជា* បានរកឃើញការយល់ដឹងស៊ីជម្រៅសំខាន់ៗចំនួនប្រាំមួយ៖

1. នៅក្នុងឆ្នាំមុន ១១% នៃកុមារដែលប្រើអ៊ីនធឺណិត អាយុពី ១២-១៧ ឆ្នាំ ក្នុងប្រទេសកម្ពុជាបានទទួលរងគ្រោះថ្នាក់ពីឧទាហរណ៍ច្បាស់លាស់នៃការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលរួមមានការត្រូវបានគំរាមឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ ការចែកចាយរូបភាពផ្លូវភេទរបស់ខ្លួនដោយគ្មានការអនុញ្ញាត ឬការត្រូវបានបង្ខំឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទតាមរយៈការសន្យាផ្តល់ប្រាក់ ឬអំណោយ។ បើវាស់ធៀបនឹងចំនួនប្រជាជនសរុប នេះតំណាងឱ្យកុមារប្រមាណ ១៦០,000 នាក់ ដែលអាចធ្លាប់បានរងគ្រោះថ្នាក់ណាមួយក្នុងរយៈពេលត្រឹមតែមួយឆ្នាំប៉ុណ្ណោះ។ ក្មេងប្រុសបានរាយការណ៍ពីបទពិសោធន៍បែបនេះស្ទើរតែពីរដងច្រើនជាងក្មេងស្រី។
2. យោងលើការស្ទង់មតិតាមខ្នងផ្ទះ ជនល្មើសភាគច្រើននៃករណី OCSEA គឺជាមនុស្សដែលស្គាល់គ្នាជាមួយកុមាររួចហើយ។ មនុស្សទាំងនេះច្រើនតែជាសមាជិកគ្រួសារ មិត្តភក្តិពេញវ័យ និងអ្នកស្គាល់គ្នា ឬដៃគូស្នេហា។ មនុស្សដែលមិនធ្លាប់ស្គាល់គ្នាជាមួយកុមារទទួលខុសត្រូវត្រឹម ១ ក្នុងចំណោម ៥ ហេតុការណ៍នៃបទល្មើសទាក់ទងនឹង OCSEA ដែលត្រូវបានកំណត់នៅក្នុងការស្ទង់មតិតាមខ្នងផ្ទះ។
3. កុមារបានជួបប្រទះបទពិសោធន៍ពាក់ព័ន្ធនឹង OCSEA ជាចម្បងតាមរយៈថ្នាលកម្មវិធីទំនាក់ទំនងសង្គមធំៗ ជាទូទៅបំផុតតាមរយៈកម្មវិធី Facebook ឬ Facebook Messenger និង កម្មវិធី WhatsApp ។
4. កុមារដែលបានទទួលរងគ្រោះថ្នាក់ពី OCSEA មានទំនោរទៅនិយាយប្រាប់មនុស្សដែលស្ថិតនៅក្នុងបណ្តាញទំនាក់ទំនងអន្តរបុគ្គលរបស់ពួកគេ ជាពិសេសមិត្តភក្តិ អ្នកថែទាំជាបុរស និងបងប្អូនបង្កើត។ បណ្តាញទូរស័ព្ទជំនួយ និងនគរបាលស្ទើរតែមិនមែនជាកន្លែងដែលកុមារទៅស្វែងរកជំនួយនោះទេ។
5. គំនិតផ្តួចផ្តើមដ៏មានសក្តានុពលជាច្រើនដែលដឹកនាំដោយរដ្ឋាភិបាល និងសង្គមស៊ីវិលកំពុងមានដំណើរការរួចហើយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែបញ្ហាប្រឈមសំខាន់ៗនៅតែកើតមាន។ សន្ទុះកើនឡើង និងការប្តេជ្ញាចិត្តដើម្បីធានាថាកុមារនៅក្នុងប្រទេសកម្ពុជាត្រូវបានការពារពី OCSEA គួរត្រូវបានប្រើប្រាស់ដើម្បីបង្កើនការយល់ដឹង ជំនាញ និងធនធានសម្រាប់អ្នកអនុវត្តច្បាប់ និងអ្នកធ្វើការខាងយុត្តិធម៌ និងគាំទ្រសង្គមកិច្ច ដើម្បីឆ្លើយតប។
6. ខណៈពេលដែលការដាក់ឱ្យប្រើប្រាស់ និងការអនុវត្តជាបន្តនូវផែនការសកម្មភាពស្តីពី OCSEA គឺជាជំហានដ៏សំខាន់មួយ ច្បាប់ គោលនយោបាយ និងបទដ្ឋានផ្សេងទៀត នៅតែចាំបាច់ត្រូវបានអនុម័ត នៅក្នុងប្រទេសកម្ពុជា។

*ការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា* គឺជាផ្នែកមួយនៃគម្រោងស្រាវជ្រាវពហុប្រទេសដែលមិនធ្លាប់មានពីមុនលើបញ្ហា OCSEA ដោយផ្តោតលើប្រទេសចំនួន ១៣ នៅតំបន់អាហ្វ្រិកខាងកើត និងខាងត្បូង និងអាស៊ីអាគ្នេយ៍។ គម្រោងសិក្សាស្រាវជ្រាវខ្នាតធំនេះផ្អែកលើឯកទេសរបស់អង្គការ ECPAT INTERPOL និងការិយាល័យស្រាវជ្រាវ Innocenti នៃអង្គការ UNICEF  និងបណ្តាញដៃគូសកលរបស់ពួកគេ។ *ការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់* ត្រូវបានគាំទ្រដោយ មូលនិធិដើម្បីបញ្ចប់អំពើហិង្សាលើកុមារ តាមរយៈគំនិតផ្តួចផ្តើម Safe Online របស់ខ្លួន។

នៅក្នុងប្រទេសកម្ពុជា ការស្រាវជ្រាវបានធ្វើឡើងចាប់ពីដើមឆ្នាំ ២០២០ ដល់ដើមឆ្នាំ ២០២១ រួមទាំងការសម្ភាសជាមួយមន្ត្រីតំណាងជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជា ព្រមទាំងស្ថាប័នសាធារណៈ និងអង្គការជាច្រើនដែលសកម្មភាពនៅក្នុងប្រទេស។ សកម្មភាពស្រាវជ្រាវរួមមានការវិភាគយ៉ាងទូលំទូលាយនៃច្បាប់ គោលនយោបាយ និងប្រព័ន្ធដែលដោះស្រាយបញ្ហា OCSEA នៅកម្ពុជា ក៏ដូចជាការសម្ភាសជាមួយអ្នកតំណាងផ្នែកយុត្តិធម៌ ការស្ទង់មតិជាមួយអ្នកផ្តល់សេវាជួរមុខ ការសន្ទនាជាមួយអ្នករស់រានមានជីវិត និងការស្ទង់មតិតាមខ្នងផ្ទះដែលមានលក្ខណតំណាងជាតិជាមួយកុមារដែលប្រើអ៊ីនធឺណិត និងអ្នកថែទាំរបស់ពួកគេ។

ទិន្នន័យពីប្រភពជាច្រើននេះត្រូវបានគេប្រៀបធៀប និងវិភាគតាមវិធានផ្សេងៗ ដើម្បីបង្កើតរបាយការណ៍ជាតិស្តីពីការបញ្ឈប់*គ្រោះថ្នាក់នៅកម្ពុជា* ។ ក្នុងដំណើរការព្រាងរបាយការណ៍*ស្តីពីការបញ្ឈប់គ្រោះថ្នាក់* នៅកម្ពុជា ក្រុមស្រាវជ្រាវបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ការពិនិត្យចុងក្រោយលម្អិតលើរបាយការណ៍របស់ក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានធ្វើឡើងនៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០២២ នៅខេត្តកំពត។

Funded by End Violence Against Children

Implemented by ECPAT INTERPOL unicef Office of Research-Innocenti